N-30
15-8-02

# ក

## មាតិកា

## I. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


| | | |
|---|---|---|
| ០៨-៨-២០០២ | -អនុក្រឹត្យលេខ ៨១ អនក្រ បក ស្តីពីការផ្ទេរឥណទានថវិកា | ២២៣៦ |
| ០៩-៨-២០០២ | -អនុក្រឹត្យលេខ ៨២ អនក្រ បក ស្តីពីការផ្ទេរឥណទានថវិកា | ២២៣៨ |
| ១៣-៨-២០០២ | -អនុក្រឹត្យលេខ ៨៣ អនក្រ បក ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការកម្មវិធី កន្សោមអាទិភាព | ២២៤០ |
| ១៣-៨-២០០២ | -អនុក្រឹត្យលេខ ៨៤ អនក្រ បក ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល | ២២៤៧ |
| ០៨-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២២៦១ |
| ០៨-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២២៦២ |
| ០៨-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ២២៦៣ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២២៦៥ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ២២៦៧ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៤០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៦៨ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៤០១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២២៦៩ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៤០២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២២៧០ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៤០៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២២៧១ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៤០៤ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ២២៧២ |
| ១២-៨-២០០២ | -អនុក្រឹត្យលេខ ៤០៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២២៧៤ |
| ១៣-៨-២០០២ | -អនុក្រឹត្យលេខ ៤០៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២២៧៥ |


### ២. សេចក្តីសំរេច


| | | |
|---|---|---|
| ១២-៨-២០០២ | - សេចក្តីសំរេចលេខ ៤១ សសរ ស្តីពីការធ្វើវិសោធនកម្មលើសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ ធ្វើជាដៃគូពិភាក្សាការងារជាមួយឯកជន | ២២៧៧ |


## II. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ០៨-៨-២០០២ | សេចក្តីជូនដំណឹងលេខ ០២២ សហវ ៧ដ ស្តីពីការទូទាត់ប្រាក់បំណុលពន្ធដារ | ២២៧៩ |

# ខ

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


១២-៨-២០០២ - ប្រកាសលេខ ២៥៨ ប្រក.កសក ស្តីពីការធ្វើនេសាទក្តាម និង ក្រែងឈាមនៅក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ២២៨០

១២-៨-២០០២ - ប្រកាសលេខ ២៥៩ ប្រក.កសក ស្តីពីការ ហាមឃាត់ក្នុងការប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទអួនក្រឡាញី្វក និងឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា ២២៨២


## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួង ពត៌មាន


១៥-៨-២០០២ - ប្រកាសលេខ ២១៥ /០២ ពម.ប្រក ស្តីពីការរៀបចំ និងការគ្រប់គ្រងកិច្ចការអាស៊ាន ២២៨៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៥០ លានរៀល ( មួយរយហាសិបលានរៀល ) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ ទូទាត់ជូនក្រុមហ៊ុន **Phnom Penh International Co.,Ltd** ដែលបានបើកប្រាក់មុនជូនដល់មន្ត្រី បុគ្គលិករំសាយចេញពីរោងចក្រហ្វីប្រូស៊ីម៉ង់ត៍។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣០.០០០ លានរៀល ( សាមសិបពាន់លានរៀលគត់ ) ពី ជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ), ជំពូក ១២ ( ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល ) និង ជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) សំរាប់បំពេញបន្ថែមបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្ស តាមកម្មវិធីកំណែទំរង់រដ្ឋបាល ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូក ជូនក្រសួង ស្ថាប័ន សាលាខេត្ត ក្រុង និង មន្ទីរជំនាញខេត្ត-ក្រុង ទៅតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យ ខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៨៣ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

## ការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ
- យោងតាមស្មារតីអង្គប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.** –

ត្រូវបានបង្កើតកន្សោមអាទិភាពនៅតាមក្រសួង ស្ថាប័ននានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តបេសកកម្មអាទិភាពរបស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើសមត្ថភាព និងលទ្ធផលការងារជាមូលដ្ឋាន ។

**មាត្រា២.** –

កន្សោមអាទិភាព គឺជាក្រុមភ្នាក់ងារចលករ ដែលធ្វើឱ្យមានការរីកចម្រើននៅក្នុងអង្គភាព និងទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័ន ក្នុងការអនុវត្តបេសកកម្មអាទិភាព ឱ្យបានសម្រេចជោគជ័យតាមគោលដៅ ដោយផ្អែកលើបទពិសោធន៍ការងារ និងជំនាញផ្សេងៗ ។

សមាជិកកន្សោមអាទិភាព ត្រូវមានជំនាញណាមួយទៅតាមប្រភេទនៃបេសកកម្មដូចជា ជំនាញលើការងារគ្រប់គ្រង ការរៀបចំគម្រោងផែនការ ការរៀបចំគម្រោងថវិកា ការងាររដ្ឋបាល ជំនាញបច្ចេកវិទ្យាព័ត៌មាន ចំណេះដឹងផ្នែកភាសាបរទេស ឬជំនាញបច្ចេកទេសចាំបាច់ដទៃទៀត ។

**មាត្រា៣.** –

ក្រសួង ស្ថាប័នសាមី ត្រូវចងក្រងបេសកកម្មអាទិភាព ផ្អែកលើផែនការសកម្មភាពអភិបាលកិច្ច ឯកសារបឋមស្តីពីយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ ផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងកម្មវិធីសកម្មភាពជាអាទិភាពរបស់រាជរដ្ឋាភិបាល ហើយរៀបចំបេសកកម្មទាំងនោះតាមលំដាប់អាទិភាព ដោយភ្ជាប់ជាមួយនូវគម្រោងសម្រាប់អនុវត្តបេសកកម្មអាទិភាពនីមួយៗ ដែលមានរយៈពេលពី ៣ ខែទៅ ១៨ ខែយ៉ាងយូរ ដើម្បីដាក់ជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលពិនិត្យ និងសម្រេច ។

**មាត្រា៤.** –

ដំណើរការកម្មវិធីកន្សោមអាទិភាពនៅដំណាក់កាលទី ១ មានរយៈពេល ៥ ឆ្នាំ គិតចាប់ពីឆ្នាំ ២០០២ ដល់២០០៦ ។ ក្នុងអំឡុងពេលនេះ រាជរដ្ឋាភិបាលអាចនឹងសម្រេចធ្វើការបញ្ឈប់ ឬបន្តកម្មវិធីកន្សោមអាទិភាពទៅតាមស្ថានភាពជាក់ស្តែង ។

## ជំពូកទី ២

## ចំនួនសមាជិកកន្សោមអាទិភាព

**មាត្រា៥.** –

ចំនួនសមាជិកកន្សោមអាទិភាពនីមួយៗរបស់ក្រសួង ស្ថាប័ននានា អាស្រ័យទៅលើប្រភេទ ទំហំ និងតម្រូវការនៃបេសកកម្មដែលត្រូវដាក់ឱ្យដំណើរការ ។

ចំនួនសមាជិកនេះ ត្រូវបានស្នើឡើងដោយក្រសួង ស្ថាប័នសាមី ហើយត្រូវសម្រេចដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា៦.-**

ចំនួនសមាជិកកន្សោមអាទិភាពសរុប ត្រូវបានគិតគូរទៅតាមលទ្ធភាពថវិកាជាតិ ដោយកំណត់យកចំនួនអតិបរមា ១០០០នាក់នៅឆ្នាំ ២០០៣ ។ នៅឆ្នាំ ២០០៤ ចំនួនសមាជិកកន្សោមអាទិភាពអាចកើនដល់ ១៥០០នាក់ជាអតិបរមា និង ២០០០នាក់ នៅឆ្នាំ ២០០៥ ហើយចំនួនអតិបរមានេះ អាចកើនដល់ ២៥០០ នាក់នៅឆ្នាំ ២០០៦ ។

ចំនួនគ្រោងទុកខាងលើអាចកើនឡើង ក្នុងករណីមានការជួយទ្រទ្រង់ពីអ្នកផ្តល់ជំនួយ និងមានការថយចុះក្នុងករណីខ្វះថវិកា ហើយអាចពន្យារពេលបាន ក្នុងករណីមានការលំបាកដោះស្រាយមិនបាន ។

## ជំពូកទី ៣
## ការជ្រើសរើស និងការបំពេញកិច្ចសន្យាការងារ

**មាត្រា៧.-**

សមាជិកកន្សោមអាទិភាព ត្រូវជ្រើសរើសដោយសម្រិតសម្រាំងចេញពីមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតនៅក្នុងក្របខ័ណ្ឌប្រភេទ ក ខ គ តាមខ្លឹមសារនៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ហើយដែលកំពុងបម្រើការងារនៅតាមក្រសួង ស្ថាប័ននានាដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានសមត្ថភាពជំនាញសមស្របទៅនឹងតម្រូវការនៃបេសកកម្ម ហើយផ្តល់អាទិភាពចំពោះមន្ត្រីរាជការជានារីភេទ ។

មន្ត្រីរាជការដែលបច្ចុប្បន្នកំពុងបម្រើការងារតាមក្រសួង ស្ថាប័ននានា ហើយបានទទួលប្រាក់ឧបត្ថម្ភពីគម្រោងផ្សេងៗ អាចត្រូវអនុញ្ញាតឱ្យជ្រើសរើសចូលជាសមាជិកនៃកន្សោមអាទិភាព លុះត្រាតែលាលែងពីគម្រោងទាំងនោះសិន។

**មាត្រា៨.-**

សមាជិកកន្សោមអាទិភាព ត្រូវបំពេញកិច្ចសន្យាតាមមុខតំណែងនីមួយៗ ។ កិច្ចសន្យានេះគឺជាលក្ខខណ្ឌការងារផ្អែកលើសមត្ថភាព និងស្នាដៃជាមូលដ្ឋាន ដែលកំណត់អំពីកាតព្វកិច្ច និងការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ បន្ថែមពីលើកាតព្វកិច្ចជាមន្ត្រីរាជការស៊ីវិលនៅក្នុងមុខងារសាធារណៈ ។

ការរៀបចំកិច្ចសន្យា ត្រូវមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់រវាងក្រសួង ស្ថាប័នសាមី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ផ្អែកលើអាណត្តិនៃបេសកកម្ម និងបទប្បញ្ញត្តិនានានៃមុខងារសាធារណៈ ។

**មាត្រា៩. –**

សមាជិកនៃកន្សោមអាទិភាពម្នាក់ៗ ឬទាំងមូល អាចត្រូវបានរំសាយមុនពេលបញ្ចប់អាណត្តិ ក្នុងករណីពុំបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ឬត្រូវកាត់ប្រាក់ឧបត្ថម្ភ ក្នុងកម្រិតណាមួយ ឬទាំងស្រុង ផ្អែកតាមការកំណត់នៃកិច្ចសន្យា ក្នុងករណីសមត្ថភាពអនុវត្តការងារមានកម្រិតទាប ឬគ្មានសមត្ថភាពអនុវត្តការងារ ។

សមាជិកនៃកន្សោមអាទិភាពម្នាក់ៗ ឬទាំងមូល អាចត្រូវជ្រើសរើសឱ្យបន្តបេសកកម្មថ្មីមួយទៀត អាស្រ័យទៅលើគុណសម្បត្តិ និងសមត្ថភាពក្នុងការបំពេញភារកិច្ច ។

## ជំពូកទី ៤

## អត្ថប្រយោជន៍សម្រាប់សមាជិកកន្សោមអាទិភាព

**មាត្រា១០. –**

សមាជិកកន្សោមអាទិភាព ត្រូវទទួលបានអត្ថប្រយោជន៍ពីរយ៉ាង គឺការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តទៅតាមលទ្ធផលការងារ និងការធ្វើសុក្រឹតការមុខជំនាញ ដែលផ្អែកលើលទ្ធភាពថវិកា និងតម្រូវការចាំបាច់នៃបេសកកម្ម ។

**មាត្រា១១. –**

សមាជិកកន្សោមអាទិភាព ដែលសម្រេចលទ្ធផលបានតាមការគ្រោងទុក និងបំពេញបានគ្រប់លក្ខខណ្ឌនៃកិច្ចសន្យា ត្រូវទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំខែ បន្ថែមពីលើប្រាក់បៀវត្សនៅក្នុងមុខងារសាធារណៈ ដូចខាងក្រោមនេះ :

- ប្រភេទ **ក** ៥២០ ០០០ រៀល ក្នុងមួយខែ
- ប្រភេទ **ខ** ៣៥០ ០០០ រៀល ក្នុងមួយខែ
- ប្រភេទ **គ** ១៩០ ០០០ រៀល ក្នុងមួយខែ ។

**មាត្រា១២. –**

កម្រិតប្រាក់ឧបត្ថម្ភសម្រាប់ប្រភេទនីមួយៗនេះ អាចពិនិត្យ និងកែសម្រួលឡើងវិញនៅក្នុងរយៈពេលនៃការអនុវត្តកម្មវិធីកន្សោមអាទិភាព អាស្រ័យលើលទ្ធភាពរបស់ថវិកាជាតិ ។

ការកែប្រែកម្រិតប្រាក់ឧបត្ថម្ភ សម្រាប់ប្រភេទនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ៥

## ការគ្រប់គ្រងដំណើរការកន្សោមអាទិភាព

**មាត្រា១៣. –**

មន្ត្រីរាជការដែលបានទទួលប្រាក់បំណាច់មុខងារតាមមាត្រា ១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែ

សម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ និងបទដ្ឋានពាក់ព័ន្ធផ្សេងទៀត មានកាតព្វកិច្ចជំរុញដំណើរការកន្សោមអាទិភាពឱ្យប្រព្រឹត្តទៅបានល្អប្រសើរ តាមការចាត់តាំងរបស់ប្រធានស្ថាប័ន ។ មន្ត្រីប្រភេទនេះ មិនត្រូវបានទទួលប្រាក់ឧបត្ថម្ភពីការអនុវត្តកម្មវិធីកន្សោមអាទិភាពឡើយ ។

**មាត្រា១៤. –**

កន្សោមអាទិភាពនៅក្នុងក្រសួង ស្ថាប័នមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័ននោះដោយមានការពិនិត្យនិងឃ្លាំមើលផ្នែកបច្ចេកទេសពីគណៈកម្មការជ្រើសរើស គណៈកម្មការតាមដានត្រួតពិនិត្យ និងគណៈកម្មការសវនកម្មនិងអធិការកិច្ច ។ គណៈកម្មការទាំងបីនេះ ត្រូវធ្វើរបាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល អំពីភាពជឿនលឿននៃការអនុវត្តកម្មវិធីកន្សោមអាទិភាពរបស់ក្រសួង ស្ថាប័ននីមួយៗ ។

ការបង្កើតគណៈកម្មការជ្រើសរើស គណៈកម្មការតាមដានត្រួតពិនិត្យ និងគណៈកម្មការសវនកម្ម និងអធិការកិច្ច ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា១៥. –**

ប្រធានស្ថាប័ននីមួយៗត្រូវចាត់តាំងអគ្គនាយក ឬអគ្គនាយករង ឬមន្ត្រីជាន់ខ្ពស់មួយរូប ជានាយកគ្រប់គ្រងកម្មវិធីកន្សោមអាទិភាព ។ នាយកគ្រប់គ្រងកម្មវិធីកន្សោមអាទិភាពមានភារកិច្ច :

- ដឹកនាំ គ្រប់គ្រង និងជំរុញដំណើរការកន្សោមអាទិភាពនៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួន
- ធានាឱ្យការងារប្រចាំថ្ងៃតាមបណ្ដាផ្នែក មានដំណើរការជាប្រក្រតី និងបញ្ចៀស ឬកាត់បន្ថយរាល់ហានិភ័យផ្សេងៗដែលអាចកើតឡើង
- រៀបចំក្រុមការងារផ្ទៃក្នុងសម្រាប់កំណត់អត្តសញ្ញាណបេសកកម្មអាទិភាព កំណត់អាទិភាពនៃបេសកកម្មអាទិភាព រៀបចំសំណើសុំដាក់ឱ្យដំណើរការកន្សោមអាទិភាព វាយតម្លៃពាក្យសុំជ្រើសរើសចូលជាសមាជិកកន្សោមអាទិភាព និងបំពេញភារកិច្ចផ្សេងៗទៀត តាមការចាំបាច់
- ធ្វើរបាយការណ៍ស្ដីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីកន្សោមអាទិភាពរៀងរាល់ខែ និងត្រីមាស ជូនប្រធានស្ថាប័ន និងជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា១៦. –**

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលមានភារកិច្ច សហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រឹក្សា និងផ្ដល់យោបល់ សំដៅជំរុញដំណើរការកន្សោមអាទិភាព ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ ។ បន្ថែមពីលើភារកិច្ចនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវធ្វើជាសេនាធិការឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ក្នុងការតាមដាន និងត្រួតពិនិត្យដំណើរការរបស់កន្សោមអាទិភាព ដើម្បីជួយតម្រង់ទិសឱ្យចំគោលដៅ ដែលរាជរដ្ឋាភិបាលបានកំណត់ ។

## ជំពូកទី ៦

## ការផ្គត់ផ្គង់ និងការគ្រប់គ្រងថវិកាទ្រទ្រង់ដំណើរការកន្សោមអាទិភាព

**មាត្រា១៧.** –

ថវិកាសម្រាប់ដំណើរការកម្មវិធីកន្សោមអាទិភាព ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ឬដោយថវិការបស់ប្រទេស ឬអង្គការផ្តល់ជំនួយ ។

**មាត្រា១៨.** –

សមាជិកគណៈកម្មការជ្រើសរើស គណៈកម្មការតាមដានត្រួតពិនិត្យ និងគណៈកម្មការសវនកម្មនិងអធិការកិច្ច ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែតាមប្រភេទក្របខណ្ឌ ដូចលក្ខខណ្ឌសមាជិកកន្សោមអាទិភាពដែរ ។

**មាត្រា១៩.** –

ការបើកប្រាក់ឧបត្ថម្ភសមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងនៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការគ្នាឱ្យបានជិតស្និទ្ធក្នុងការរៀបចំកំណត់នីតិវិធី និងបើកផ្តល់ថវិកាសម្រាប់ដំណើរការកន្សោមអាទិភាពអោយបានទាន់ពេលវេលា ហើយត្រូវខិតខំកៀងគររកជំនួយបន្ថែមទៀត ដើម្បីពង្រីកលទ្ធភាពនៃការអនុវត្តកម្មវិធីឱ្យបានទូលំទូលាយ ។

**មាត្រា២០.** –

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាអ្នកសម្របសម្រួលការពិភាក្សារវាងអ្នកផ្តល់ជំនួយនិងក្រសួង ស្ថាប័ន។ មូលនិធិសម្រាប់កម្មវិធីកន្សោមអាទិភាព ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា២១.** –

កម្មវិធីកន្សោមអាទិភាព ត្រូវដាក់ឱ្យដំណើរការពីឆ្នាំ ២០០២ នេះតទៅ ដោយចាប់ផ្តើមពីការអនុវត្តកន្សោមអាទិភាពដំបូង ដឹកនាំដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីធ្វើឱ្យកន្សោមអាទិភាពនៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តបេសកកម្មអាទិភាពរបស់ខ្លួន ។ កន្សោមអាទិភាពដំបូងនេះ នឹងប្រើប្រាស់ផងដែរ ជាមធ្យោបាយសម្រាប់ដកស្រង់បទពិសោធន៍ ត្រួសត្រាយផ្លូវឱ្យកន្សោមអាទិភាព ដែលនឹងត្រូវបង្កើតជាបន្តបន្ទាប់នៅតាមក្រសួង ស្ថាប័នដំណើរការបានល្អតាមទិសដៅកំណត់ ។

# ជំពូកទី ៨

# អវសានប្បញ្ញត្តិ

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២២
- គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណរដ្ឋបាល

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស /រកម/០១៩៦/១៣/ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខនស /រកម/០១៩៦/១៨/ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១២៩៧ /៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ០៤ /អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០២

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

សាលាមធ្យមសិក្សាកសិកម្មព្រែកលៀប ត្រូវប្ដូរឈ្មោះជាសាលាជាតិកសិកម្មព្រែកលៀប សរសេរកាត់ ក.ព.ល នឹង ត្រូវសម្រេចឱ្យទៅជាគ្រឹះស្ថានសាធារណរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា២.-**

ក.ព.ល ជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ។ ក.ព.ល មានអាសយដ្ឋាន ផ្លូវជាតិ ៦អា សង្កាត់ព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ការផ្លាស់ប្ដូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ ក.ព.ល ។

**មាត្រា៣.-**

ក.ព.ល មានភារកិច្ចនិងសិទ្ធិដូចតទៅ ÷

- បណ្ដុះបណ្ដាលអ្នកបច្ចេកទេសកសិកម្ម និងកសិ ឧស្សាហកម្មគ្រប់កម្រិតជាអាទិភាព សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសកសិកម្ម តាមប្រព័ន្ធដែលមានលក្ខណៈទ្រឹស្ដី និង ការអនុវត្តបណ្ដុះបណ្ដាល និងបំប៉នមុខជំនាញវិជ្ជាជីវៈកសិកម្ម និងកសិឧស្សាហកម្មតាមសំណូមពរចាំបាច់របស់សង្គម

- មានសិទ្ធិសហការជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម សាកលវិទ្យាល័យ វិទ្យាស្ថាននានាក្នុង - ក្រៅប្រទេស និង ធ្វើទំនាក់ទំនងសហប្រតិបត្តិការនិងចុះកិច្ចសន្យាជាមួយអង្គការជាតិអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័ននិងក្រុមហ៊ុននានា ដើម្បីធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវគុណភាពចំណេះដឹង ខាងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេសកសិកម្ម គប្បី :

-រៀបចំកម្មវិធីសិក្សាដើម្បីសុំការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា

- ផ្ដល់ និង រួមផ្ដល់ជាមួយគ្រឹះស្ថានបណ្ដុះបណ្ដាលកសិកម្មដទៃទៀត នូវវិញ្ញាបនបត្រឬសញ្ញាបត្រកម្រិតជាតិ

-សិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រកសិកម្ម

- រៀបចំ និង ដំណើរការការងារជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន ប្រឡងចេញ វាយតម្លៃការសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព

- កសាងផែនការមូលដ្ឋានសម្ភារៈ

- កសាងគម្រោងផែនការអភិវឌ្ឍឱ្យបានសមស្របទៅតាមសភាពការណ៍រីកចម្រើនរបស់ប្រទេសជាតិ

- គ្រប់គ្រងមន្ត្រីរាជការ និយោជិក កម្មករ សិស្ស និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិ ។

## ជំពូកទី២

## រដ្ឋបាល និង ការគ្រប់គ្រង

### ផ្នែកទី១

### ក្រុមប្រឹក្សាភិបាល

**មាត្រា៤.-**

ក.ព.ល ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខ័ណ្ឌតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

**មាត្រា៥.-**

៥.១ - ក្រុមប្រឹក្សាភិបាលមានសមាជិក ៧រូប ដែលមានសមាសភាពដូចតទៅ :

- តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន
- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាង ក្រសួងអប់រំយុវជន និងកីឡា សមាជិក
- នាយក សាលាជាតិកសិកម្មព្រែកលៀប សមាជិកស្វ័យប្រវត្តិ
- ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធន៍ខ្ពស់ សមាជិក
- តំណាង បុគ្គលិកសាលាកសិកម្មព្រែកលៀប សមាជិកស្វ័យប្រវត្តិ

៥.២- ប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំង ដោយអនុក្រឹត្យ សម្រាប់អាណត្តិ៣ (បី) ឆ្នាំ រៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ក្រសួងឬអាជ្ញាធរដែលខ្លួនតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងឬអាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

៥.៣-តំណាងបុគ្គលិក ក.ព.លត្រូវបានជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម បុគ្គលិក ក.ព.ល ។

**មាត្រា៦.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី៦៥ ឆ្នាំ និង មានបទពិសោធន៍ការងារគ្រប់គ្រាន់ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ចវិទ្យាសាស្ត្រ អប់រំឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និង ពុំដែលធ្លាប់ទទួលទោសព្រហ្មទណ្ឌកម្រិតធ្ងន់ពីតុលាការឡើយ ។

**មាត្រា៧.-**

៧.១- ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីកោះប្រជុំនិងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

៧.២- ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើវិស័យបណ្តុះបណ្តាលកសិកម្ម គ្រប់គ្រងសេដ្ឋកិច្ចកសិកម្ម អភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម ការងារស្រាវជ្រាវ កសិកម្ម និង តំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនេះ មានសិទ្ធិផ្តល់មតិតែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិសដៅ និង ធ្វើការត្រួតពិនិត្យលើដំណើរការរបស់សាលាជាតិកសិកម្មព្រែកលៀប ។

ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវ :

- ពិនិត្យនិងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ ក.ព.ល ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យនិងសម្រេចលើចំណូលនិងចំណាយជាប្រចាំព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ ក.ព.ល
- ពិនិត្យនិងសម្រេចលើរបាយការណ៍គ្រប់គ្រង និង លើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់និងរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅ ដល់អង្គភាពក្រោមឱវាទ
- កំណត់នូវរបបជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក ក.ព.ល ដោយមិនប៉ះពាល់ដល់បទបញ្ញត្តិច្បាប់ឬបទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះភ្នាក់ងារមុខងារសាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់ ក.ព.ល
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្ម
- កំណត់បទបញ្ជាផ្ទៃក្នុង ក.ព.ល .
- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបានតាមគោលដៅកំណត់ដោយ ក.ព.ល ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

**មាត្រា៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់នាយកសាលាជាតិកសិកម្មព្រែកលៀប ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១០.-**

១០.១- ក្រុមប្រឹក្សាភិបាលនៃ ក.ព.ល ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើសមាជិក ចំនួន២/៣ (ពីរភាគបី) ឡើងទៅឬតាមការស្នើសុំពីនាយក ក.ព.ល ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ ដែលមានវ័យច្រើនជាងគេក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាល វត្តមានដើម្បីដឹកនាំការប្រជុំ ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ១ (មួយ) រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច១០ (ដប់) ថ្ងៃមុនថ្ងៃប្រជុំ ។

១០.២- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមានចំនួនលើសពី៥០ (ហាសិប) ភាគរយនៃសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ ប្រសិនបើសំឡេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែ លើរបៀបវារៈនៃការអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន មួយ ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបានលុះត្រាតែមានការអនុម័ត ដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន ។

ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព ។

១០.៣- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយតម្កល់ទុកនៅទីស្នាក់ការ ក.ព.ល នឹងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះ ត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ នឹងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួង ពាក់ព័ន្ធយ៉ាង យូរ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ ។

១០.៤- ក.ព.ល ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ ÷

- កំណត់ហេតុនៃការប្រជុំ របស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍ របស់សាលាជាតិកសិកម្មព្រែកលៀប
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥- ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនឱ្យហួសពី១៥ (ដប់ប្រាំ) ថ្ងៃ ។

## ជំពូកទី២

## អង្គការប្រតិបត្តិរបស់សាលាជាតិកសិកម្មព្រែកលៀប

**មាត្រា១១.-**

ក.ព.ល ត្រូវគ្រប់គ្រងដោយនាយកមួយរូប ដែលជានាយកសាលាកសិកម្មព្រែកលៀបត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នាយកនេះមានតួនាទីជានាយកប្រតិបត្តិ ។

**មាត្រា១២.-**

១២.១- នាយក ក.ព.ល មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រងនិងអនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

នាយកមានភារកិច្ច ÷

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល

- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវនយោបាយដែលកំណត់ដោយក្រុមប្រឹក្សានេះ

- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ ក.ព.ល ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច

- ធ្វើរបាយការណ៍ប្រចាំឆ្នាំរាល់សកម្មភាព ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ឯកសារទាំងនេះ ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច

- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ

- បំពេញរាល់មុខតំណែងរបស់ ក.ព.ល ក្នុងការកម្រិតក្របខ័ណ្ឌ ចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក

- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលនៃ ក.ព.ល

- សម្រេចលើការងារលទ្ធកម្ម និង ចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត ស្តីពីបញ្ហានេះ

ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យតាមបទបញ្ជាផ្ទៃក្នុងរបស់ ក.ព.ល និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២- នាយកនៃ ក.ព.ល ជាតំណាងសាលាក្នុងការទំនាក់ទំនងជាមួយតតិយជន ។

១២.៣- នាយកនៃ ក.ព.ល ត្រូវស្នើទៅក្រុមប្រឹក្សាភិបាល ដើម្បីក្រុមប្រឹក្សានេះស្នើសុំតែងតាំងនាយករង មួយរូប ឬច្រើនរូបសម្រាប់ជួយការងាររបស់ខ្លួនតាមការចាំបាច់ ។

uc

## ជំពូកទី៣
## បុគ្គលិករបស់ " គ.ព.ល "

**មាត្រា១៣.-**

១៣.១- បុគ្គលិកអចិន្ត្រៃយ៍របស់ គ.ព.ល រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬជ្រើសរើសតាមសំណើរបស់នាយកនៃ គ.ព.ល ។ មន្ត្រីទាំងនេះ ត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

១៣.២- គ.ព.ល អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យាជំនួយការនិងបុគ្គលិកអណ្តែត។ ភ្នាក់ងារទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ ។

១៣.៣- បុគ្គលិក គ.ព.ល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្តីពីបុគ្គលិកសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាល កំណត់ប្រាក់កម្រៃលើកទឹកចិត្ត ចំពោះបុគ្គលិកព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី៤
## ទ្រព្យសម្បត្តិរបស់ " គ.ព.ល "

**មាត្រា១៤.-**

១៤.១- គ.ព.ល ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនៈវត្ថុដូចតទៅ ÷

- ដីជាទីតាំងនៃ គ.ព.ល មានផ្ទៃដី៣០ហិកតា ស្ថិតនៅសង្កាត់ព្រែកលៀប ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ( ស្ថិតនៅលើផ្ទៃដីអតីតវិទ្យាល័យកសិកម្មព្រែកលៀប ) និង ៣០០ហិកតា ស្ថិតនៅ ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។
- អាគាររដ្ឋបាល អាគារសិក្សា អន្តេវាសិកដ្ឋាន ស្ថានីយ៍ចិញ្ចឹមសត្វ ស្ថានីយ៍ដំណាំ កសិដ្ឋានចិញ្ចឹមត្រី កសិដ្ឋាន ដាំឈើ អាគារសហសិក្សា អាគារមន្ទីរពិសោធន៍ ។

១៤.២- ក្រៅពីអចលនទ្រព្យខាងលើ គ.ព.ល ត្រូវបានទទួលនូវអចលនទ្រព្យ និងចលនទ្រព្យផ្សេងៗដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣- អចលនទ្រព្យនិង ចលនទ្រព្យទាំងអស់របស់ គ.ព.ល នឹងមានចែងលំអិតក្នុងបញ្ជីសារពើភ័ណ្ឌ ។

១៤.៤- គ.ព.ល អាចទិញលក់ចលនទ្រព្យ និងទិញអចលនទ្រព្យ ចាំបាច់សម្រាប់ដំណើរការរបស់ខ្លួន ។

## ជំពូកទី៥

## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ " ក.ព.ល "

**មាត្រា១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ ក.ព.ល ត្រូវប្រព្រឹត្ត ស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពី បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ។

**មាត្រា១៦.-**

១៦.១- នាយក ក.ព.ល ជាអាណាប័កដើមខ្សែរបស់សាលា ហើយត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និង ទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

១៦.២- អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬ បុរេប្រទានបានដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា១៧.-**

១៧.១- ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោម តាមបទបញ្ជាផ្ទៃក្នុងរបស់ ក.ព.ល ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែឥតមានសំឡេងឆ្នោតឡើយ ។

១៧.២- ភ្នាក់ងារគណនេយ្យមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុកនិងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់សាលា
- រក្សាទុកលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣ - ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការរបស់ខ្លួនបាន ។

**មាត្រា១៨.-**

១៨.១ - ប្រភពធនធាន ក.ព.ល រួមមាន :

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់ ក.ព.ល នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ

- អំណោយ ជំនួយនិងអច្ច័យទានដែល ក.ព.ល បានទទួល

- ប្រាក់ខ្ចីបុលដោយ ក.ព.ល ផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ ក.ព.ល

- ផលនៃការងារ និង កម្រៃនៃការផ្តល់សេវាផ្សេងៗដោយ ក.ព.ល

- កម្រៃនៃការជួលទ្រព្យសម្បត្តិរបស់ ក.ព.ល និង ចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាត ពីរាជរដ្ឋាភិបាល

- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ ក.ព.ល ។

១៨.២- ចំណូលនិងចំណាយជាប្រចាំព្រមទាំងមូលធនរបស់ ក.ព.ល ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាលា ។ ក្រុមប្រឹក្សាភិបាល ក.ព.ល ត្រូវបែងចែកអំពីបែបបទនៃការរៀបចំការចាត់ចែង និងអនុវត្តថវិកា ។

សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំការចាត់ចែង និង អនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣- ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែនៃ ក.ព.ល. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការ សម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែ កញ្ញា ក្នុងឆ្នាំទីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និង ចំណាយ ។

**មាត្រា១៩.-**

១៩.១ - ការងារគណនេយ្យរបស់ ក.ព.ល រួមមាន ÷

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិការតនាគារ និងប្រតិបត្តិការ ដែលអនុវត្តជាមួយតតិយជន

- គណនេយ្យ អសង្ហារឹម រូបធាតុ និង គណនេយ្យតម្លៃ

- គណនេយ្យ វិភាគប្រសិនបើជាការចាំបាច់

គណនេយ្យរបស់សាលាត្រូវ :

១ - ស្របតាមវិធានដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២ - គោរពតាមប្លង់គណនេយ្យរបស់ ក.ព.ល ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ប្លង់គណនេយ្យនេះត្រូវទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៩.២- គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សាលា ត្រូវរៀបចំដោយភ្នាក់ងារ គណនេយ្យនិងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយ របាយការណ៍គ្រប់គ្រងដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច លើឯកសារទាំងនោះយ៉ាងយូរ៣(បី)ខែក្រោយ ការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា២០.-**

មូលនិធិរបស់ ក.ព.ល គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំ បាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាម ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ផ្នែកទី៦**

**របបសារពើពន្ធនៃ " ក.ព.ល "**

**មាត្រា២១.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ ក.ព.ល. ត្រូវស្ថិតនៅក្រោមនីតិរូបចំពោះរបប សារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

**ផ្នែកទី៧**

**លទ្ធកម្មរបស់ " ក.ព.ល "**

**មាត្រា២២.-**

ការសម្រេច ការអនុវត្តនិងការត្រួតពិនិត្យលើលទ្ធកម្មរបស់ ក.ព.ល ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិ នៃអនុក្រឹត្យ លេខ៦០ អនក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងបទបញ្ញាដទៃទៀត ពាក់ព័ន្ធនឹងបញ្ហានេះ ។

**ជំពូកទី៣**

**ផ្នែកទី១**

**អាណាព្យាបាលបច្ចេកទេស**

**មាត្រា២៣.-**

២៣.១- ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក ក.ព.ល ត្រូវផ្ញើជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និង គម្រោង ថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រយៈពេល១ ( មួយ ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានពេល២ (ពីរ )ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយ នាយកដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២ - លិខិតផ្តល់យល់ព្រមត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឬតំណាង ហើយត្រូវផ្ញើជូនទៅនាយក ក.ព.ល ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកនៃ ក.ព.ល ត្រូវបញ្ជូនព័ត៌មាននេះ ឱ្យទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

uc

ក្នុងករណីដែលរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍឬគម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍនៃ ក.ព.ល និងថវិកាចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័នឬអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំទាំបំបែកជា១២ ( ដប់ពីរ ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័នឬអាណាព្យាបាលបច្ចេកទេស ។

**មាត្រា២៤.-**

២៤.១ - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបញ្ជូនមក ខ្លួនដូចមានចែងក្នុងមាត្រា២៣ខាងលើ មាន ÷កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្តីពីការ គ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានរយៈពេល ១ ( មួយ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នោះ ។

២៤.២- នាយក ក.ព.ល ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការ ជំទាស់របស់រដ្ឋមន្ត្រីក្រសួង កសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិភាក្សា ឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនោះ សេចក្តីសម្រេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរ ដល់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា២៥.-**

២៥.១- រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អាចលុបឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬ នាយកនៃ ក.ព.ល ក្នុងករណីដែលសេចក្តីសម្រេច នោះ ÷

- ផ្ទុយ ឬមាននិន្នាការផ្ទុយនឹងគោលដៅរបស់ ក.ព.ល
- ផ្ទុយ ឬមាននិន្នាការផ្ទុយនឹងច្បាប់ និង បទបញ្ជា
- ធ្វើផ្ទុយ ឬមាននិន្នាការផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២- ការលុបចោលឬការផ្អាកទុកនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដោយមានបញ្ជាក់ពីមូលហេតុ តាមគំនិតផ្ទាល់ខ្លួនឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងលាយលក្ខណ៍អក្សរដល់នាយក ក.ព.ល ហើយ នាយកត្រូវជូន ព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា២៦.-**

រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អាចចាត់ឱ្យធ្វើអធិការកិច្ចឬការត្រួតពិនិត្យការងារ ក្នុង សាលាក្នុងករណីដែលយល់ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និង បែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិ ដែលមានជាធរមាន ។

## ជំពូកទី២

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា២៧.-**

២៧.១ - ក្នុងរយៈពេល១៥(ដប់ប្រាំ )ថ្ងៃបន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក ក.ព.ល ត្រូវធ្វើ របាយការណ៍ ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានរយៈពេល១ ( មួយ )ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេល២ ( ពីរ )ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយនាយក ក.ព.ល ដើម្បីផ្តល់ ការយល់ព្រមលើឯកសារទាំងនោះ ។

២៧.២ - លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើទៅនាយក ក.ព.ល ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

នាយក នៃ ក.ព.ល ត្រូវជូនព័ត៌មាននេះ ដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុម ប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាល ឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ ទាំងនោះ ។

របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេច យល់ព្រមបានឡើយក្នុង ករណី ដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា២៨.-**

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះ របស់ក្រុមប្រឹក្សាភិបាលឬនាយក គ.ព.ល ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមមាន ÷

- សេចក្តីសម្រេច ស្តីពីការលក់ ឬ ផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានាឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា២៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យមួយរូបប្រចាំ គ.ព.ល ដែល មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុននិងជាក្រោយលើ គ.ព.ល ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា តាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា៣០.-**

៣០.១ - ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ គ.ព.ល ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.២ - ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគណនេយ្យកណ្តាលនៃរតនាគារជាតិនិងក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០.៣ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចាត់ចែងផ្ទៀងផ្ទាត់ធ្វើអធិការកិច្ចឬត្រួតពិនិត្យលើសាលាទៅពេលដែលយល់ថាចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

# ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ពន្ធ័ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០២

**ហ៊ុន សែន**

***កន្លែងទទួល :***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:**...៣៩៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **ព្រាំ តារាឧត្តម** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៩៦ អនក្រ.តត

## អនុក្រឹត្យ

### ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

### សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ហ៊ុន សារិន** ជាប្រធាននាយកដ្ឋានសៀវភៅ និង ការអាន នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរៈសេនីយ៍ទោ **ស សុនា** អត្តលេខ ០៧០០ អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ។

២- លោកវរៈសេនីយ៍ទោ **សួន សុគន្ធ** អត្តលេខ ០៦៧៥ អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ។

៣- លោកវរៈសេនីយ៍ទោ **លៀង អៀង** អត្តលេខ ០៨៦១ អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ។

៤- លោកវរៈសេនីយ៍ទោ **អ៊ុត សិទ្ធិ** អត្តលេខ ០៦៧៩ អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ។

៥- លោកវរៈសេនីយ៍ទោ **អ៊ុន សុវណ្ណធី** អត្តលេខ ០៣៨៧ អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ។

៦- លោកវរៈសេនីយ៍ទោ **ពេជ្រ តុង** អត្តលេខ ០៧១៧ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧១៥ អនក.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីនៃក្រសួងធនធានទឹក និង ឧតុនិយម ចំនួន ២២ រូប ដែលមានស្នាដៃល្អ ក្នុងការរួមចំណែកយ៉ាងសកម្ម នៅការដ្ឋានជួសជុលទំនប់ការពារទឹកជំនន់កប់ស្រូវ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ÷

**ក ~ មេដាយមាសការងារ :**

| | | | | |
|---|---|---|---|---|
| ១ - | ឯកឧត្តម | **ណឹ** | **លន់** | អគ្គាធិការ |
| ២ - | លោក | **មុី** | **លីហួត** | អគ្គនាយករង កិច្ចការរដ្ឋបាល |
| ៣ - | លោក | **ជួន** | **មិត្តថុល** | អគ្គនាយករង កិច្ចការបច្ចេកទេស |
| ៤ - | លោក | **ស៊ិន** | **វុទ្ធី** | ប្រធាននាយកដ្ឋានរដ្ឋបាល និង ធនធានមនុស្ស |
| ៥ - | លោក | **ជិង** | **សេងអ៊ីម** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ៦ - | លោក | **ឯម** | **ម៉ុនធឿន** | ប្រធាននាយកដ្ឋានវិស្វកម្ម |
| ៧ - | លោក | **តែ** | **ណាវុធ** | ប្រធាននាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេ |
| ៨ - | លោកស្រី | **សិទ្ធិ** | **វណ្ណារ៉េត** | ប្រធាននាយកដ្ឋានឧតុនិយម |

**ខ - មេដាយប្រាក់ការងារ :**

១ - លោក **លឹម ចេង** អនុប្រធាននាយកដ្ឋានវិស្វកម្ម

២ - លោក **ចាំង វិយុទ្ធជា** អនុប្រធាននាយកដ្ឋានគ្រប់គ្រង និង អភិរក្សធនធានទឹក

៣ - លោក **ជួន វណ្ណារិទ្ធ** ប្រធានការិយាល័យបុគ្គលិក នាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស

៤ - លោក **លឹម វិរក្ស** ប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានវិស្វកម្ម

៥ - លោក **សង់ វិសាល** អនុប្រធានការិយាល័យបុគ្គលិកនាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស

៦ - លោក **សៅ សម្ផស្ស** អនុប្រធានការិយាល័យបណ្តុះបណ្តាលនាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស

**គ - មេដាយសំរិទ្ធការងារ :**

១ - លោក **ប្រាក់ សំអឿន** ប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានហិរញ្ញវត្ថុ

២ - លោក **ហង់ ដៃយ៉ាណា** អនុប្រធានការិយាល័យសំណង់ នាយកដ្ឋានវិស្វកម្ម

៣ - លោក **នេត សាម៉ល់** ប្រធានផ្នែកសន្តិសុខ

៤ - លោក **ហ៊ាន ហឿន** អ្នកបើកបររថយន្ត

៥ - លោក **ទ្រឹក សួស្តី** ប្រធានផ្នែកពត៌មាន

៦ - លោក **ចាន់ យុត្ថា** នាយកខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី

៧ - លោក **ទើ ចេង** អនុប្រធាបមន្ទីរធនធានទឹក និង ឧតុនិយម រាជធានីភ្នំពេញ

៨ - លោក **ជឹម គីរម្យ** មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៩៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សំរេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សរឫទ្ធិ** ជូនឯកឧត្តម **ម៉ុន ហ៊ាន** អគ្គនាយកកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹក និង ឧតុនិយម ដែលមានស្នាដៃល្អ ក្នុងការរួមចំណែកយ៉ាងសកម្ម នៅការដ្ឋានជួសជុលទំនប់ការពារទឹកជំនន់កប់ស្រូវ រាជធានីភ្នំពេញ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤០០ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលស្រុកពញាឮ ខេត្តកណ្តាល

**សំរេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកគ្រូ ខេមរៈមហាចក្រ **ម៉ៅ រិទ្ធីថា** ប្រធានសមាគម ពុទ្ធសាសនូបត្ថម្ភសង្គ្រោះចាស់ជរា ជនក្រីក្រ និង ក្មេងកំព្រា ដែលបានធ្វើអំណោយជួយកសាងវិស័យសង្គមកិច្ច និងព្រះពុទ្ធសាសនា អស់ទឹកប្រាក់ចំនួន ៤៨.១៧០ USD និង ៣៧.១២០.០០០ រៀល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤០១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

ៜៜៜៜៜ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី **Helen Pitt** អតីតទីប្រឹក្សាក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា និង ជានាយិកាប្រតិបត្តិ នៃក្រុមប្រឹក្សាសកម្មភាពជនពិការ ដែលបានជួយលើវិស័យសង្គមកិច្ច ជនពិការ និង កុមារ ហើយស្វែងរកជំនួយបានចំនួន ២.២២០.០០០ USD ជួយដល់ប្រជាជនកម្ពុជា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤០៥...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **Peter Logan** មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី ( **ADB** ) ដែលបានមកបំពេញការងារ សហការស្តារប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ពីឆ្នាំ ១៩៩៤ ដល់ ១៩៩៦ និងថ្មីៗនេះបានជួយសហការស្តារទំនប់ការពារទឹកជំនន់កប់ស្រូវ រាជធានី - ភ្នំពេញ ទទួលបានលទ្ធផលល្អ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:**....៤០៣...អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **Christopher Devey** មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី (**ADB**) ដែលបានចូលរួមសហការ ក្នុងការងារស្តារប្រព័ន្ធធារាសាស្ត្រ នៅកម្ពុជា ពីឆ្នាំ២០០១ ដល់ បច្ចុប្បន្ន ទទួលបានលទ្ធផលល្អ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៩០៤...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ជូនឯកឧត្តម អស់លោក ចំនួន ១៨ រូប ដែលមានស្នាដៃល្អ ក្នុងការសហការការងារ នៅការដ្ឋានជួសជុលទំនប់ការពារទឹកជំនន់កប់ស្រូវ រាជធានីភ្នំពេញ ដូចមាននាមខាងក្រោម ÷

**ក-មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ :**

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

២- ឯកឧត្តម **ស៊ុំ មានិត** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី

**ខ-មេដាយសុវត្ថារា** ថ្នាក់ **សេនា :**

១- ឯកឧត្តម **អ៊ី គីហ៊ាង** រដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

២- ឯកឧត្តម **ចៅ ពិន** រដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

៣- ឯកឧត្តម **សំ សារិត** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

៤- ឯកឧត្តម **ផង់ សារ៉េត** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

៥- ឯកឧត្តម **វេង សាខុន** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

៦- ឯកឧត្តម **តុំ ប៊ុនធឿន** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

៧- ឯកឧត្តម **អៀវ ហ៊ុនលី** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម

**គ.មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ :**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយត្រី | **ម៉ៅ** | **សុផាន់** | មេបញ្ជាការ កងពលតូចលេខ ៧០ |
| ២- លោក | **ឃឹម** | **បូរ** | អភិបាលរងទី១ ខេត្តកណ្តាល |
| ៣- លោក | **ម៉ក់** | **សំអឿន** | អភិបាលរងទី៣ ខេត្តកណ្តាល |
| ៤-វរសេនីយឯក | **ជួន** | **សុវណ្ណ** | មេបញ្ជាការ កងរាជអាវុធហត្ថ ខេត្តកណ្តាល |
| ៥- វរសេនីយឯក | **ហែម** | **ថារ** | មេបញ្ជាការរង កងពលតូចលេខ ៧០ |
| ៦- វរសេនីយឯក | **ចាន់** | **វណ្ណារ** | មេបញ្ជាការរង កងពលតូចលេខ ៧០ |
| ៧- វរសេនីយឯក | **ជួង** | **សារី** | មេបញ្ជាការរង កងពលតូចលេខ ៧០ |
| ៨- លោក | **ទូច** | **សារុន** | អភិបាលខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ |
| ៩- លោក | **តាំ** | **វៃ** | ស្នងការរង នគរបាល ខេត្តកណ្តាល |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៤០៦...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី ដែលមានស្នាដៃល្អ ក្នុងការសហការការងារនៅការដ្ឋានជួសជុល ទំនប់ការពារទឹកជំនន់កប់ស្រូវ រាជធានីភ្នំពេញ ដូចមាននាមខាងក្រោម ÷

**ក-មេដាយប្រាក់ការងារ**

១- លោក **យ៉ាវ ឡើន** ប្រធានមន្ទីរខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

២- លោក **ប្រាក់ ចាន់ណា** ប្រធានការិយាល័យរដ្ឋបាលខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៣- លោក **ហ៊ូ សាម៉ន** ក្រុមប្រឹក្សាសង្កាត់ស្វាយប៉ាកខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៤- លោក **រិទ្ធ ចិត្រា** នាយកវិទ្យុបាយ័ន

**ខ-មេដាយសំរិទ្ធការងារ**

- លោក **យឿន ពេជ្រតារា** មន្ត្រីសុខាភិបាល ខេត្តកណ្តាល

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

.......

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញអនុក្រឹត្យ លេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតម្លើងអធិការដ្ឋានរបស់ក្រសួងបរិស្ថាន ទៅជាអគ្គាធិការដ្ឋាន

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំរេច

**មាត្រា១ .-**

ត្រូវបានតែងតាំង :

១- លោក **ឈុរ ថាវណារិត** បច្ចុប្បន្នជាប្រធាននាយកដ្ឋានអធិការកិច្ច នៃក្រសួងបរិស្ថាន ជាអគ្គាធិការរងទទួលបន្ទុករួម នៃអគ្គាធិការដ្ឋាន ។

២- លោក **ឌឹម រដ្ឋា** បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងបរិស្ថាន ជាអធិការ នៃអគ្គាធិការដ្ឋាន ។

៣- លោក **អ៊ឹង សេខ** បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងបរិស្ថាន ជាអធិការ នៃអគ្គាធិការដ្ឋាន ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ៧ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល*** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការធ្វើវិសោធនកម្មលើ

## សេចក្តីសំរេចលេខ ៤៤សសរ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០១

## ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន
- អនុលោមតាមតំរូវការចាំបាច់

# សម្រេច

**ប្រការ១:** កែសំរួលភារកិច្ចក្នុងប្រការ១ នៃសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០១ ត្រង់ចំណុច :

- "គ" «ក្រុមការងារផ្នែកកម្មន្តសាល និងចែកចាយ » ដោយអានថា : "គ" «ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច-មធ្យម » វិញ ។
- "ឆ" «ក្រុមការងារផ្នែកផលិតកម្មកែច្នៃ ដើម្បីនាំចេញ» ដោយអានថា : "ឆ" «ក្រុមការងារផ្នែកផលិតកម្មកែច្នៃសំរាប់នាំចេញ និងកិច្ចសំរួលពាណិជ្ជកម្ម » វិញ ។

**ប្រការ២:** ប្រការ ៧ និងប្រការ ៨ នៃសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣:** ក្រៅពីការកែសំរួលភារកិច្ច ដូចមានចែងក្នុងប្រការ១ និងការចាត់ទុកជានិរាករណ៍ដូចមានចែងក្នុងប្រការ២ខាងលើ ខ្លឹមសារនៃសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា - សហរដ្ឋមន្ត្រី - រដ្ឋមន្ត្រី - រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនឹងសមាសភាពក្នុងក្រុមការងារ ដែលបានធ្វើការកែសំរួល ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២២ សហវ.៣៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការទូទាត់ប្រាក់បំណុលពន្ធរដ្ឋ

អនុលោមតាមច្បាប់ស្ដីពីសារពើពន្ធដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងរំលឹកជាចុងក្រោយបង្អស់ដល់លោក-លោកស្រី ជានាយកក្រុមហ៊ុនដែលជំពាក់បំណុលពន្ធរដ្ឋ សូមអញ្ជើញមកធ្វើការទូទាត់សងបំណុលពន្ធអោយបានចប់សព្វគ្រប់មុនថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០២ ជាកំហិត ។ ករណីមិនបានមកទូទាត់បំណុលពន្ធតាមកាលបរិច្ឆេទខាងលើនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងអនុវត្តយ៉ាងតឹងរឹងបំផុតតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្ដីពីសារពើពន្ធទៅតាមករណីនីមួយៗដែលរួមមាន : ការឃាត់ទុកគណនីនៅធនាគារ ឬ រតនាគារជាតិ បញ្ឈប់រាល់ប្រតិបត្តិការនាំចេញ-នាំចូល ទុកជាមោឃៈនូវលិខិតអនុញ្ញាតិ និងអាជ្ញាប័ណ្ណផ្សេងៗ និង រឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនលោកដើម្បីធ្វើការដេញថ្លៃលក់យកប្រាក់មកទូទាត់បំណុលពន្ធ ប្រាក់ទោសទណ្ឌព្រមទាំងប្រាក់ ចំណាយក្នុងការប្រមូលពន្ធ ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជឿជាក់ថា លោក-លោកស្រី ប្រាកដជាបានយល់ដឹង និង យកចិត្តទុកដាក់បំពេញកាតព្វកិច្ចបង់បំណុលពន្ធជូនរដ្ឋតាមពេលវេលាកំណត់ខាងលើជាពុំខាន ។

សូមលោក-លោកស្រី ជ្រាបនិងអនុវត្តតាមច្បាប់កំណត់ ។/.

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ 258 ប្រក.កសក

# ប្រកាស

## ស្តីពី

## ការធ្វើនេសាទក្តាម និង ក្រែងឈាម នៅក្នុងដែននេសាទសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ប្រកាសលេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និង សមុទ្រ
- បានឃើញ ប្រកាសលេខ ០០០២ ប្រក.កសក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៨៩ ស្តីពីអង្គការមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទ វារីវប្បកម្ម កែច្នៃជលផល និងការអនុញ្ញាតពិសេស
- តាមសំណើរបស់ នាយកដ្ឋានជលផល

## សំរេច

**ប្រការ១** : ការធ្វើនេសាទក្តាម និង ក្រែងឈាម នៅក្នុងដែននេសាទសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ ។

**ប្រការ២** : ត្រូវហាមឃាត់ :

១. ការធ្វើនេសាទក្ដាម ដោយប្រើប្រាស់ឧបករណ៍ទាំងឡាយណាធ្វើពីសាច់អួន ឬ សាច់មង ដែលមានក្រឡាតូចជាង ៦ស.ម ។

២. ការធ្វើនេសាទក្រែងឈាម ដោយប្រើប្រាស់ឧបករណ៍ទាំងឡាយណាធ្វើពីសាច់អួន ឬ សាច់មង ដែលមានក្រឡាតូចជាង ២ស.ម ។

៣ ការធ្វើអាជីវកម្មនេសាទ ការទិញ ការលក់ សន្និធិ ឬ ការដឹកជញ្ជូន :

ក- ក្ដាមថ្ម ដែលមានប្រវែងស្នូក ខ្លីជាង ៨ ស.ម ឬ ច្រើនជាង ១០ក្បាលក្នុង១ គីឡូក្រាម ។

ខ- ក្ដាមសេះ និង ក្ដាមខ្លា ដែលមានប្រវែងស្នូក ខ្លីជាង ៩ស.ម ឬ ច្រើនជាង ២០ក្បាលក្នុង១ គីឡូក្រាម ។

គ- ក្រែងឈាម ដែលមានប្រវែងខ្លីជាង ២ ស.ម ឬច្រើនជាង៣០០គ្រាប់ក្នុង ១គីឡូក្រាម ។

**ប្រការ៣** : ជនណាដែលបានប្រព្រឹត្តល្មើសនឹងប្រការ១ ឬ/និង ប្រការ២ នៃប្រកាសនេះ ត្រូវផ្ដន្ទាទោសតាមមាត្រា៣៨ មាត្រា៣៩ ឬ មាត្រា៤០ នៃក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល ។

**ប្រការ៤** : ជនណាឆ្លៀតយកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួន ដើម្បីប្រព្រឹត្តបទល្មើស ឬ ឃុបឃិតបិទបាំង ការពារអំពើល្មើស ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦** : អគ្គនាយក នៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋាន កិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការ អន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង និងប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី 12 ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចិន្ដា-ភារ៉ែន

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សាលាខេត្ត ក្រុង ពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ 259 ប្រក.កសក

## ប្រ កា ស

**ស្តីពី**

**ការហាមឃាត់ក្នុងការប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទអួនក្រឡាញឹក និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា**

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ប្រកាសលេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និង សមុទ្រ
- តាមសំណើរបស់ នាយកដ្ឋានជលផល

## ស ម្រេ ច

**ប្រការ១** : ហាមដាច់ខាតការធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទអួនក្រឡាញឹកដែលមានក្រឡាតូចជាង ១,៥សង្ទីម៉ែត្រ និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២** : ហាមដាច់ខាត ការដឹកជញ្ជូន ការទិញ ការលក់ ការរក្សាទុក និង/ឬសន្និធិប្រភេទធនធានជលផល ដែលបានមកពីការធ្វើនេសាទល្មើសច្បាប់ ដោយឧបករណ៍នេសាទអួនក្រឡាញ៉ឹក និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ។

**ប្រការ៣** : ជនណាដែលបានប្រព្រឹត្តល្មើសនឹងប្រការ១ ឬ/និង ប្រការ២ នៃប្រកាសនេះ ត្រូវផ្តន្ទាទោសតាមមាត្រា៣៨ មាត្រា៣៩ ឬ មាត្រា៤០ នៃក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ។

**ប្រការ៤** : ជនណាឆ្លៀតយកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួន ដើម្បីប្រព្រឹត្តបទល្មើស ឬ ឃុបឃិតបិទបាំង ការពារអំពើល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦** : អគ្គនាយក នៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋាន កិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការ អន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង និងប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី 12 ខែ [illegible] ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចន្ទ សារុន

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សាលាខេត្ត ក្រុង ពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពត៌មាន

MINISTRY OF INFORMATION

**ក្រសួងពត៌មាន**

**MINISTRY OF INFORMATION**

លេខ ២១៥/០២ ព.ម ប្រ-ក

រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការរៀបចំនិងការគ្រប់គ្រងកិច្ចការអាស៊ាន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២-នស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ-បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ២១-អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង ៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ
- យោងតាមតម្រូវការចាំបាច់ក្នុងការរៀបចំ និងការគ្រប់គ្រងកិច្ចការអាស៊ានឡើងវិញ

## សំរេច

**ប្រការ ១:** ដកការិយាល័យអាស៊ាន ពីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មកដាក់ក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ២:** តែងតាំង ឯកឧត្តម **សាមួន ជិន** អនុរដ្ឋលេខាធិការ ជាប្រធានគណៈកម្មាធិការជាតិវប្បធម៌ និងពត៌មាន អាស៊ាន-កម្ពុជា និង ត្រូវទទួលបន្ទុកគ្រប់គ្រងការិយាល័យអាស៊ានដោយផ្ទាល់ ។

**ប្រការ ៣:** តែងតាំង លោក **ហ៊ឹម សួន** អគ្គនាយករងនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ជាប្រធានអនុគណៈកម្មាធិការពត៌មាន នៃគណៈកម្មាធិការជាតិវប្បធម៌ និងពត៌មានអាស៊ាន-កម្ពុជា ។

**ប្រការ ៤:** តែងតាំង លោក **ឃាស់ សំអាត** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវប្បធម៌ និងពត៌មាន អាស៊ាន-កម្ពុជា ។

**ប្រការ ៥:** ឯកឧត្តមអគ្គនាយកគ្រប់អគ្គនាយកដ្ឋានចំណុះ ប្រធាននាយកដ្ឋានបុគ្គលិក នាយកខុទ្ទកាល័យ និងសាមីខ្លួន ត្រូវអនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ រាល់បទបញ្ញត្តិទាំងឡាយដែលផ្ទុយពីប្រកាស នេះ ត្រូវទុកជានិរាករណ៍ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

ស៊ី.ឡាយផូលវិន

**ចំលងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួង មន្ទីរពាក់ព័ន្ធ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ "ដើម្បីជ្រាប"
-ដូចប្រការ ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ